សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់
"គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីនដល់CMAC (ដំណាក់កាលទី៣)"
**២១ កញ្ញា ២០១៦**

- **សូមគោរព ឯកឧត្តម ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC)!**
- **សូមគោរពលោក ស៊ីបាតា មិគីអុ ប្រធានតំណាងអង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)!**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយ សម្រាប់"គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីនដល់CMAC(ដំណាក់កាលទី៣)" ដែលនឹងត្រូវបានអនុវត្តដោយអង្គការកំចាត់មីនជប៉ុនJMAS ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា កម្ពុជាមានគ្រាប់មីនមិនទាន់ផ្ទុះជាច្រើនដែលត្រូវបានកប់ក្នុងសម័យពីសង្គ្រាម ជាពិសេសនៅភូមិភាគពាយព្យ។ វត្តមាននៃគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គឺមិនត្រឹមតែគំរាមគំហែងដល់សុវត្ថិភាពប្រជាជនប៉ុណ្ណោះទេ ថែមទាំងជាឧបសគ្គដ៏ធំមួយសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច សេដ្ឋកិច្ច និងកសិកម្ម ក៏ដូចជាការអភិវឌ្ឍជនបទផងដែរ ដូច្នេះហើយ ការបោសសម្អាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់នេះចេញ គឺជាដំណើរការមួយដែលសំខាន់មិនអាចខ្វះបានទេ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ CMAC ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកនេះ ចំនួនជនរងគ្រោះដែលបណ្តាលមកពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានការថយចុះទៅពីមួយឆ្នាំទៅមួយឆ្នាំ។ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តឧបត្ថម្ភគាំទ្រដល់សកម្មភាពបោសសម្អាតមីននៅកម្ពុជា តាមរយៈជំនួយឧបត្ថម្ភឥតសំណង ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស។ យ៉ាងណាមិញ ឆ្នាំមុននេះ នៅតែមានជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះប្រមាណជាង១១០នាក់។ ដោយសារតែស្ថានភាពបែបនេះ ទើបតំរូវការ និងភាពចាំបាច់នៃសកម្មភាពបោសសម្អាតមីន នៅតែមានអត្រាខ្ពស់ដដែរ។

នៅក្នុងស្ថានភាពបែបនេះ អង្គការJMAS បានសហការជាមួយCMAC ដើម្បីអនុវត្តនូវសកម្មភាពរបស់ខ្លួនជាបន្តបន្ទាប់ហូតដល់១៣ខេត្ត ចាប់តាំងពីឆ្នាំសារពើពន្ធឆ្នាំ២០០២មក តាមរយៈជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលជាគ្រោងការណ៍ជំនួយហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ប្រទេសជប៉ុន។ អស់រយៈពេលជាច្រើនឆ្នាំមកនេះ អង្គការJMAS ទទួលបានជោគជ័យក្នុងការបន្តធ្វើសកម្មភាពរបស់ខ្លួនជាច្រើនរួមមាន៖ ការបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក៏ដូចជាការផ្ទេរបច្ចេកទេសនិងជំនាញជាច្រើនដល់CMAC ដែលជាការរួមចំណែកដ៏ធំធេងក្នុងការកសាងសន្តិភាពនៅកម្ពុជា។

នៅក្នុងឆ្នាំទី៣នៃគម្រោងដែលទើបតែបានចុះហត្ថលេខានៅថ្ងៃនេះ រដ្ឋាភិបាលជប៉ុន ផ្តល់ជូនថវិកាប្រមាណជា ៨៣ម៉ឺនដុល្លាអាមេរិកដល់អង្គការJMAS ដើម្បីជួយដល់ការផ្ទេរនូវបច្ចេកទេសបោសសម្អាតមីន និងការរៀបចំបង្កើតសមត្ថភាពដល់ CMAC តាមរយៈកម្មវិធីសិក្សាថ្មីមួយ ដែលមានឈ្មោះថា "កម្មវិធីសិក្សាបោសសម្អាតមីនរួមបញ្ចូលគ្នា" ដែលជាគម្រោងបន្ទាប់តពីគម្រោងឆ្នាំទី១ និងឆ្នាំទី២ របស់អង្គការJMAS។ គម្រោងនេះ នឹងអនុវត្តជាក់ស្តែងនូវការបោសសម្អាតមីននៅក្នុងចំការមីនប្រមាណជា ២៦០ហិចតា ក្នុងឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ដែលជាផ្នែកមួយនៃការបណ្តុះបណ្តាល។ ខ្ញុំទទួលដំណឹងថា អង្គការJMAS បានអនុវត្តគម្រោងជួយស្តារឡើងវិញនូវតំបន់អតីតចំការមីន តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធ និងអគារសិក្សានានាជាដើម នៅលើដីធ្លីដែលបានបោសសម្អាតមីនរួចហើយនោះ ក្រោមមូលនិធិរបស់អង្គការតែម្តង។

គម្រោងនេះ ត្រូវបានផ្តោតជាសំខាន់លើគោលដៅនាពេលអនាគត ដើម្បីសម្រេចបាននូវការលុបបំបាត់ភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម តាមរយៈការបោសសម្អាតមីន ក៏ដូចជាការបង្កើនភាពជាដៃគូជាសកល ដើម្បីដោះស្រាយបញ្ហាគ្រាប់មីន ដែលជាបញ្ហាទូទៅលើឆាកអន្តរជាតិ តាមរយៈកិច្ចសហប្រតិបត្តិការត្បូង-ត្បូងរបស់CMAC និងកិច្ចសហប្រតិបត្តិការត្រីកោណ។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងរួមចំណែកយ៉ាងធំធេងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ដែលត្រូវបានអនុម័តកាលពីឆ្នាំមុននៅឯមហាសន្និបាតអង្គការសហប្រជាជាតិ ដែលជាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍(MDGs)។

ជាចុងក្រោយនេះ ក្រោមគ្រោងការណ៍ជំនួយឧបត្ថម្ភសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជំនួយដែលចាំបាច់ដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន សម្រាប់អនុវត្តគម្រោងអភិវឌ្ឍផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងតំបន់គោលដៅ ព្រមទាំងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចស្រាប់មកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**